Eat Well, Live Well.

AJINOMOTO®

# AGP

## Ajinomoto Group Policies

Khmer

ភាសាខ្មែរ

# មាតិកា


**សារពីលោកប្រធាននិងអគ្គនាយកប្រតិបត្តិ** ........ 1

Our Philosophy ........ 2

AGP (Ajinomoto Group Policies) ........ 3

- វិសាលភាពនៃការអនុវត្ត ........ 4
- ការទទួលខុសត្រូវរបស់ក្រុមហ៊ុន ........ 4
- បណ្ដាញហ៊ិតឡាញ ........ 4
- យើងខ្ញុំគាំទ្រ “អនុសញ្ញាសកល” របស់អង្គការសហប្រជាជាតិ ........ 5
- យើងខ្ញុំធ្វើសកម្មភាពយ៉ាងសកម្មក្នុងការគាំទ្រការសម្រេចនៃគោលដៅអភិវឌ្ឍដោយនិរន្តរភាព។ ........ 5

1. **គំនិតផ្ដួចផ្ដើមកែលំអរអាហារូបត្ថម្ភ** ........ 6
2. **ការផ្គត់ផ្គង់ផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់និងសុវត្ថិភាពល្អ** ........ 7
3. **វិភាគទានចំពោះបរិស្ថាននិងនិរន្តរភាពនៃផែនដី** ........ 8
4. **ប្រតិបត្តិការប្រកបដោយតម្លាភាពនិងយុត្តិធម៌** ........ 8
5. **សកម្មភាពពាក់ព័ន្ធនឹងសិទ្ធិមនុស្ស** ........ 10
6. **ការបណ្ដុះបណ្ដាលបុគ្គលិក និង ការធានាសុវត្ថិភាព** ........ 11
7. **ធ្វើការងារនឹងសហគមន៍** ........ 12
8. **ការទទួលខុសត្រូវចំពោះម្ចាស់ហ៊ុននិងវិនិយោគិន** ........ 13
9. **ការការពារនិងគ្រប់គ្រងទ្រព្យសម្បត្តិនិងព័ត៌មានរបស់ក្រុមហ៊ុន** ........ 14
10. **ការបែងចែកឱ្យដាច់ នូវបញ្ហាឯកជននិងបញ្ហាអាជីវកម្ម** ........ 15
11. **ការរៀបចំនិងការអនុវត្តអភិបាលកិច្ចល្អ** ........ 16

- របាយការណ៍ ........ 17


## សារពីលោកប្រធាននិងអគ្គនាយកប្រតិបត្តិ



បេសកកម្មរបស់យើងខ្ញុំនៅ Ajinomoto Group គឺការធ្វើជាវិភាគទានចំពោះចំណីអាហារ និងសុខភាពល្អនៃពិភពលោក ព្រមទាំងជីវភាពរស់នៅល្អសម្រាប់អនាគត។ ហេតុនេះហើយបានជាយើងបានផ្ដួចផ្ដើមស្វែងរក ASV (The Ajinomoto Group Creating Shared Value) - នេះគឺជាវិធីសាស្ត្រដ៏ពិសេសមួយដើម្បីដោះស្រាយបញ្ហាសង្គមតាមរយៈអាជីវកម្មរបស់យើង និងអភិវឌ្ឍតម្លៃសេដ្ឋកិច្ចតាមរយៈការបង្កើតតម្លៃជារួមជាមួយនឹងសង្គម ព្រមទាំងសហគមន៍មូលដ្ឋាន។

ការស្វែងរក ASV នេះ ចាំបាច់ត្រូវមានសហប្រតិបត្តិការពីសំណាក់ម្ចាស់ហ៊ុននិងវិនិយោគិននានា ហើយសហប្រតិបត្តិការនេះអាចកើតមានឡើងតែតាមរយៈការខំប្រឹងប្រែងយ៉ាងខ្លាំងរបស់ Ajinomoto យើងខ្ញុំក្នុងការទទួលនូវទំនុកចិត្តពីសង្គម។ ដោយសារតែបានយល់ឃើញបែបនេះហើយ បានជាយើងខ្ញុំបានធ្វើកំណែអំពីគោលការណ៍ដែលឆ្លុះបញ្ចាំងនូវជំនឿនិងឥរិយាបទដែលក្រុមហ៊ុន Ajinomoto Group និងបុគ្គលិកម្នាក់ៗត្រូវលើកកំពស់ ហើយដែលយើងបានដាក់ឈ្មោះថា The Ajinomoto Group Policies (AGP)។ AGP នេះគឺជាទស្សនៈមូលដ្ឋានរួម និងជាសកល ហើយក៏ដូចជាក្រមប្រតិបត្តិ ដែលយើងត្រូវគោរពតាមក្នុងការធ្វើសកម្មភាពអាជីវកម្មរបស់ Ajinomoto Group ដោយគោរពច្បាប់នៃប្រទេស ឬតំបន់នីមួយៗដែលយើងដំណើរការ និងគោរពវិន័យអន្តរជាតិពាក់ព័ន្ធនឹង “បញ្ហាក្នុងសង្គមមនុស្សសតវត្សរ៍ទី២១” និងការផ្ដួចផ្ដើមស្វែងរក ASV។

គោលការណ៍ AGP ត្រូវអនុវត្តទៅលើសកម្មភាពទាំងអស់របស់យើងខ្ញុំ ហើយផ្ដល់នូវការសន្យាជាលាយលក្ខណ៍អក្សរចំពោះម្ចាស់ហ៊ុននិងវិនិយោគិនរបស់យើងខ្ញុំទាំងអស់ ដែលយើងខ្ញុំត្រូវគាំទ្រ។ គោលដៅរបស់យើងខ្ញុំគឺ ឱ្យក្លាយទៅជាក្រុមហ៊ុនដែលមានលក្ខណៈពិសេសក្នុងពិភពលោក ដែលទទួលបាននូវជំនឿទុកចិត្តទៅលើសកម្មភាពនានាដែលយើងខ្ញុំធ្វើដើម្បីលើកកំពស់ AGP។



លោក Taro Fujie
តំណាងនាយកប្រតិបត្តិ
ប្រធាននិងអគ្គនាយកប្រតិបត្តិនៃ Ajinomoto Co., Inc.

## Our Philosophy

តាំងពីពេលដែលត្រូវបានបង្កើតឡើងមក Ajinomoto Group យើងខ្ញុំបានសន្យាធ្វើការផ្តួចផ្តើមដោះស្រាយបញ្ហាសង្គមតាមរយៈអាជីវកម្មរបស់យើងខ្ញុំជារៀងរហូតមក។ ការផ្តួចផ្តើមទាំងនេះបានធ្វើវិភាគទានដល់ការលូតលាស់របស់ក្រុមយើងខ្ញុំ ដោយសារកំណើននៃតម្លៃសេដ្ឋកិច្ច តាមរយៈការបង្កើតតម្លៃរួមជាមួយនឹងសង្គម ព្រមទាំងសហគមក្នុងមូលដ្ឋាន។ ការផ្តួចផ្តើមទាំងនេះ យើងខ្ញុំហៅថា ASV (The Ajinomoto Group Creating Shared Value)។ ASV គឺជាស្នូលនៃ Our Philosophy ហើយដែលជាវិធីដើម្បីសម្រេចនូវបេសកកម្មនិងចក្ខុវិស័យរបស់ក្រុមយើងខ្ញុំក្រោមទស្សនវិជ្ជានេះ។

បាវចនារបស់ក្រុមហ៊ុន

**Eat Well, Live Well.**




**វិធីអនុវត្តនៃ Ajinomoto Group**

Ajinomoto Group Policies (AGP)

## AGP (Ajinomoto Group Policies)

មូលដ្ឋានគ្រឹះនៃ ASV បេសកកម្មនិងចក្ខុវិស័យរបស់យើងខ្ញុំ គឺ គោលការណ៍និងទស្សនៈវិស័យនៃ Ajinomoto Group ឬ “AGP” យើងខ្ញុំ។ គោលការណ៍ទាំងនេះបង្ហាញនូវជំនឿ និងឥរិយាបទដែលក្រុមហ៊ុននិងបុគ្គលិកនៃក្រុមហ៊ុន Ajinomoto Group ទាំងអស់ត្រូវប្រកាន់យក។ គោលការណ៍នេះក៏មានតួនាទីជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរចំពោះម្ចាស់ហ៊ុននិងវិនិយោគិនដែលយើងខ្ញុំត្រូវខំប្រឹងប្រែងបំពេញការងារយ៉ាងហ្មត់ចត់ដើម្បីទ្រទ្រង់ជំនឿនិងឥរិយាបទទាំងនេះ។

រូបខាងក្រោមនេះបង្ហាញអំពីទំនាក់ទំនងរវាងកត្តាសំខាន់ៗនៃទស្សនៈវិស័យរបស់យើងខ្ញុំ។

ហេតុផលនៃការរស់រានមានជីវិត បេសកកម្ម និងចំណង់ចិត្តរបស់យើងខ្ញុំក្នុងនាមជាក្រុមហ៊ុនដែលយើងត្រូវគាំទ្រជានិរន្តរ។

**បេសកកម្មរបស់យើងខ្ញុំគឺធ្វើវិភាគទានចំពោះចំណីអាហារ និងសុខភាពពិភពលោក ព្រមទាំងជីវភាពរស់នៅកាន់តែល្អនាអនាគត។**

អ្វីដែលជាគោលដៅរបស់យើងខ្ញុំក្នុងការគាំទ្របេសកកម្មរបស់យើងខ្ញុំ

**ប្រើប្រសិទ្ធភាពរបស់អាមីណូអាស៊ីដក្នុងការដោះស្រាយបញ្ហាចំណីអាហារនិងសុខភាព ដែលពាក់ព័ន្ធនឹងទម្លាប់របបអាហារនិងភាពចាស់ ដើម្បីជាវិភាគទានដល់សុខភាពរបស់ប្រជាជនទូទាំងពិភពលោក។**

នៅឆ្នាំ 2030
- ជួយក្នុងការពន្យាអាយុកាលដែលមានសុខភាពល្អរបស់ប្រជាជនចំនួន 1000លាននាក់។
- កាត់បន្ថយនូវផលប៉ះពាល់ទៅលើបរិស្ថានឱ្យបាន 50% ខណៈដែលអាជីវកម្មមានការកើនឡើង។

ផ្តួចផ្តើមបង្កើតតម្លៃទាំងសង្គម ទាំងសេដ្ឋកិច្ច ដើម្បីឱ្យបានសម្រេចនូវបេសកកម្មនិងចក្ខុវិស័យយើងខ្ញុំ។

**ASV គឺជាកិច្ចសន្យាមិនប្រែប្រួលរបស់យើងខ្ញុំ : យើងជួយក្នុងការដោះស្រាយបញ្ហាសង្គម និងនាំមុខក្នុងការបង្កើតតម្លៃសេដ្ឋកិច្ចជាមួយនឹងម្ចាស់ហ៊ុននិងវិនិយោគិន និងអាជីវកម្មរបស់យើង។**

តម្លៃជារួមរវាងបុគ្គលិកក្នុងការស្វែងរកបេសកកម្មនិងចក្ខុវិស័យ;
វិធីគ្រឹះនិងគោលជំហររបស់យើងដែលត្រូវប្រកាន់ក្នុងការបំពេញការងារ

- **បង្កើតតម្លៃថ្មី**
- **ស្មារតីត្រួសត្រាយផ្លូវ**
- **វិភាគទានដល់សង្គម**
- **ឱ្យតម្លៃមនុស្ស**

ជំនឿនិងឥរិយាបទដែលក្រុមហ៊ុននីមួយៗ និងបុគ្គលិកម្នាក់ៗនៃ Ajinomoto Group ត្រូវប្រកាន់

## វិសាលភាពនៃការអនុវត្ត

គោលការណ៍និងទស្សនៈវិស័យនៃ Ajinomoto Group ឬ “AGP” ត្រូវអនុវត្តចំពោះក្រុមហ៊ុន និងអ្នកដឹកនាំ និង បុគ្គលិកទាំងអស់នៃ Ajinomoto Group។

## ការទទួលខុសត្រូវរបស់ក្រុមហ៊ុន

- ក្រុមហ៊ុននីមួយៗនៃ Ajinomoto Group មិនចេញបញ្ជាចំពោះអ្នកដឹកនាំ ឬបុគ្គលិករបស់ខ្លួនឱ្យប្រព្រឹត្តផ្ទុយនឹង “ក្រមប្រតិបត្តិ” នេះឡើយ។ ម៉្យាងទៀត ក្រុមហ៊ុននីមួយៗនៃ Ajinomoto Group មិនដាក់ទោសធ្វើឱ្យបាត់បង់ផលប្រយោជន៍អ្នកដឹកនាំ ឬបុគ្គលិក ដោយមូលហេតុថាអ្នកនោះបានគោរព “ក្រមប្រតិបត្តិ” នេះឡើយ។
- ថ្នាក់ដឹកនាំនៃក្រុមហ៊ុននីមួយនៃ Ajinomoto Group ត្រូវយល់ដឹងអំពីតួនាទីរបស់ខ្លួនក្នុងការគោរពតាម AGP នេះ និងបង្កើតជាឧទាហរណ៍គំរូនៃការគោរពច្បាប់ ហើយត្រូវនាំមុខក្នុងការអនុវត្តតាម ព្រមទាំងធានានូវការគោរពច្បាប់ក្នុងក្រុមហ៊ុន ហើយបង្កើតនូវប្រព័ន្ធខាងក្នុងដែលមានប្រសិទ្ធិភាពបញ្ចូលនូវមតិរបស់អ្នកខាងក្នុងនិងខាងក្រៅក្រុមហ៊ុន។
- នៅពេលមានការរំលោភធ្ងន់ធ្ងរទៅលើ AGP ដូចជា ច្បាប់និងបទដ្ឋានគតិយុត្ត ជាដើម ថ្នាក់ដឹកនាំនៃក្រុមហ៊ុននីមួយៗ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីគោលជំហររបស់ខ្លួនជូនម្ចាស់ហ៊ុននិងវិនិយោគិន ហើយខំប្រឹងស្រាវជ្រាវនូវមូលហេតុ និងចាត់វិធានការបង្ការកុំឱ្យបញ្ហាដូចគ្នានោះកើតមានឡើងជាថ្មីម្តងទៀត។

## បណ្តាញហ៊ុតឡាញ

- Ajinotomo Group បានបង្កើតវិធីសម្រាប់បុគ្គលិកធ្វើរបាយការណ៍ស្តីពីសកម្មភាពបំពានច្បាប់ និងបញ្ហាពាក់ព័ន្ធនឹង “គោលការណ៍ជារួមនៃក្រុមតាមរយៈការផ្តល់របាយការណ៍អនាមិក” ដែលមានពន្យល់ក្នុងជំពូកទី១១។
- ក្រុមហ៊ុននៃ Ajinomoto Group នឹងរក្សាការពារការសម្ងាត់របស់ឯកបុគ្គលទាំងអស់ដែលបានធ្វើរបាយការណ៍ ហើយធានាថា មិនប្រើរបាយការណ៍ទាំងនេះ ដើម្បីធ្វើឱ្យខូចផលប្រយោជន៍អ្នកធ្វើរបាយការណ៍ឡើយ។

- **យើងខ្ញុំគាំទ្រ “អនុសញ្ញាសកល” របស់អង្គការសហប្រជាជាតិ**

“អនុសញ្ញាសកលរបស់អង្គការសហប្រជាជាតិ” គឺជាគំនិតផ្តើមដោយស្ម័គ្រចិត្ត ដែលអង្គការសហប្រជាជាតិបានស្នើចំពោះសហគ្រាស ហើយដែលមានគោលការណ៍មូលដ្ឋាន១០ ស្តីពីសិទ្ធិមនុស្ស ស្តង់ដារការងារ បរិស្ថាន ការបង្ការអំពើពុករលួយ ដូចតទៅ។

| សិទ្ធិមនុស្ស | សហគ្រាសត្រូវ |
|---|---|
| គោលការណ៍ទី១ | គាំទ្រ និងគោរពសិទ្ធិមនុស្សដែលប្រកាសដោយអន្តរជាតិ |
| គោលការណ៍ទី២ | ធានាដោយខ្លួនឯងថា មិនចូលរួមក្នុងការបំពានសិទ្ធិមនុស្ស។ |
| **បទដ្ឋានការងារ** | **សហគ្រាសត្រូវ** |
| គោលការណ៍ទី៣ | គាំទ្រនូវការទទួលស្គាល់សិទ្ធិសេរីភាពនៃការបង្កើតសហជីព និងសិទ្ធិចរចាជាសមូហភាព |
| គោលការណ៍ទី៤ | គាំទ្រនូវការបំបាត់នូវការងារដោយបង្ខំគ្រប់ប្រភេទ |
| គោលការណ៍ទី៥ | គាំទ្រនូវការលុបចោលប្រកបដោយអានុភាព នូវការប្រើកម្លាំងពលកម្មលើកុមារ |
| គោលការណ៍ទី៦ | គាំទ្រនូវការលុបចោលនូវការរើសអើងការងារនិងការរកបុគ្គលិក។ |
| **បរិស្ថាន** | **សហគ្រាសត្រូវ** |
| គោលការណ៍ទី៧ | គាំទ្រជាគោលការណ៍ ចំពោះវិធីការពារបញ្ហាបរិស្ថាន |
| គោលការណ៍ទី៨ | ទទួលខុសត្រូវខ្លាំងចំពោះបញ្ហាបរិស្ថាន |
| គោលការណ៍ទី៩ | អភិវឌ្ឍ និងខំប្រឹងប្រែងផ្សព្វផ្សាយអំពីបច្ចេកទេសល្អសម្រាប់បរិស្ថាន។ |
| **ការបង្ការនូវអំពើពុករលួយ** | **សហគ្រាសត្រូវ** |
| គោលការណ៍ទី១០ | ធ្វើសកម្មភាពការពារកុំឱ្យមានអំពើពុករលួយគ្រប់បែបយ៉ាង រួមទាំងការបង្ខំ និងការសូកនិងទទួលសំណូក។ |

- **យើងខ្ញុំធ្វើសកម្មភាពយ៉ាងសកម្មក្នុងការគាំទ្រការសម្រេចនៃគោលដៅអភិវឌ្ឍដោយនិរន្តរភាព។**

គោលដៅអភិវឌ្ឍដោយនិរន្តភាព (SDGs) ត្រូវបានសម្រេចដោយអង្គប្រជុំកំពូលនៃអង្គការសហប្រជាជាតិនៅខែកញ្ញា ឆ្នាំ២០១៥ សម្រាប់ការអភិវឌ្ឍដោយនិរន្តរភាពដល់ឆ្នាំ២០៣០ ជំនួសគោលដៅនៃការអភិវឌ្ឍសហសវត្សរ៍ ដែលត្រូវបានសម្រេចនៅឆ្នាំ២០០១។ នៅក្នុង SDGs នេះ មានគោលដៅទាំងអស់ ១៧ចំណុច ដែលទូទាំងពិភពលោកបានព្រមព្រៀង សម្រាប់ឆ្នាំ២០១៦ ដល់ឆ្នាំ២០៣០។

## 1. គំនិតផ្តួចផ្តើមកែលំអរអាហារូបត្ថម្ភ

1.1 យើងខ្ញុំមើលទៅលើតម្រូវការនៃអាហារូបត្ថម្ភនៃប្រជាជនក្នុងតំបន់នានា ដែលមានអាយុជីវភាពរស់នៅ និងស្ថានភាពសុខភាពខុសៗគ្នា ព្រមទាំងផ្តត់ផ្គង់ផលិតផល និងផ្តល់ព័ត៌មានស្តីពីតុល្យភាពអាហារូបត្ថម្ភនៃចំណីអាហារប្រចាំថ្ងៃ។

1.2 យើងធ្វើវិភាគទានចំពោះការលូតលាស់ផ្លូវចិត្តនិងផ្លូវកាយ មិនត្រឹមតែតាមរយៈការផ្គត់ផ្គង់ផលិតផលប៉ុណ្ណោះទេ គឺយើងផ្គត់ផ្គង់នូវរបស់ដែលមានជីវជាតិត្រឹមត្រូវ ហើយថែមទាំងតាមរយៈការណែនាំអំពីម្ហូបអាហារឆ្ងាញ់ៗ ម្ហូបសំបូរបែប ការចំអិនអាហារដោយឆ្លាតវៃ និងការហូបជាមួយគ្នា។

1.3 យើងធ្វើសកម្មភាពជួយអ្នកប្រើប្រាស់ក្នុងការកែលំអអាហារូបត្ថម្ភ តាមរយៈការជូននូវព័ត៌មាននានា ការផ្គត់ផ្គង់ផលិតផល និងសេវាកម្មដោយផ្អែកទៅលើការយល់ដឹងដោយស៊ីជម្រៅអំពីស្ថានភាពក្នុងសហគមន៍។

1.4 យើងខ្ញុំផ្តល់ឱកាសឱ្យអាចទទួលបាននូវចំណីអាហារដោយមានអាហារូបត្ថម្ភ តាមរយៈផលិតផលក្នុងតម្លៃសមល្មម និងតាមវិធីសមស្រប ត្រូវនឹងតម្រូវការនៃប្រទេសនីមួយៗ។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីអាហារូបត្ថម្ភ
2. គោលការជារួមក្នុងក្រុមស្តីពីការទទួលបាននូវផលិតផល

## 2. ការផ្គត់ផ្គង់ផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់និងសុវត្ថិភាពល្អ

2.1 យើងខ្ញុំត្រូវប្រើបច្ចេកទេសល្អៗ និងគំនិតច្នៃប្រឌិតសំបូរបែប ដើម្បីអភិវឌ្ឍផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់និងសុវត្ថិភាព ដោយគិតអតិថិជនជាចំបង ជានិច្ចជាកាល។

2.2 យើងខ្ញុំត្រូវផ្តល់នូវព័ត៌មានត្រឹមត្រូវហើយមានប្រយោជន៍ស្តីពីផលិតផលនិងសេវាកម្មរបស់យើងខ្ញុំ ដើម្បីទទួលនិងរក្សាជំនឿពីអតិថិជន ហើយសម្របទៅនឹងការរំពឹងទុករបស់អ្នកទាំងនោះ ហើយឱ្យគេស្របចិត្ត។

2.3 យើងខ្ញុំធានាថា ម៉ាយេធីង និងការផ្សាយពាណិជ្ជកម្មរបស់យើងខ្ញុំ ត្រូវបានធ្វើឡើងដោយមានឥទ្ធិពលទៅវិញទៅមកនឹងអតិថិជនយើងខ្ញុំ ព្រមទាំងតាមវិធីដែលមានការទទួលខុសត្រូវ ជាពិសេសពេលមានការពាក់ព័ន្ធផ្ទាល់នឹងកុមារ។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីគុណភាព
2. គោលការណ៍ជារួមក្នុងក្រុមស្តីពីសុវត្ថិភាពចំណីអាហារ
3. គោលការណ៍ជារួមក្នុងក្រុមស្តីពីការប្រាស្រ័យទាក់ទងក្នុងម៉ាយេធីង
4. គោលការណ៍ជារួមក្នុងក្រុមស្តីពីការសរសេរលើកញ្ចប់

## 3. វិភាគទានចំពោះបរិស្ថាននិងនិរន្តរភាពនៃផែនដី

3.1 យើងធ្វើការងារជាមួយសហគមន៍និងអតិថិជន ដើម្បីឱ្យអាចរស់នៅដោយសុខដុមនឹងផែនដី និងដើម្បីឆ្ពោះទៅរក "សង្គមមួយដែលមានការកែច្នៃឡើងវិញ" ដោយនិរន្តរភាព។

3.2 យើងខ្ញុំម្នាក់ៗក៏ត្រូវលើកកំពស់ការប្រើធនធានធម្មជាតិ ឬ ថាមពលឱ្យមានប្រសិទ្ធិភាពខ្ពស់ និងការគិតដល់បរិស្ថាន។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីបរិស្ថាន
2. គោលការណ៍ជារួមក្នុងក្រុមស្តីពីសុខុមាលភាពសត្វ

## 4. ប្រតិបត្តិការប្រកបដោយតម្លាភាពនិងយុត្តិធម៌

4.1 ចំពោះប្រតិបត្តិការទាំងអស់របស់យើងខ្ញុំៗខំប្រឹងប្រែងរក្សាជានិច្ចនូវយុត្តិធម៌ និងតម្លាភាព និងទទួលស្គាល់ភាគីជាដៃគូដ៏សំខាន់នៃកិច្ចការជំនួញរបស់យើងខ្ញុំ។

4.2 យើងខ្ញុំត្រូវចាត់វិធានការឱ្យយល់ច្បាស់អំពីការគោរពច្បាប់ហាមឯកាធិភាព និងច្បាប់ពាក់ព័ន្ធនឹងការប្រកួតប្រជែងនៃប្រទេសនីមួយៗដែលយើងខ្ញុំប្រកបអាជីវកម្ម។ យើងមិនចូលរួមឃុបឃិតជាមួយនឹងគូប្រជែងយើងខ្ញុំ ដើម្បីកំណត់តម្លៃ ឬការលក់ / បរិមាណនៃការផលិត ដើម្បីកម្រិតនូវការប្រកួតប្រជែង (ការតែល) ឬជជែកគ្នាអំពីការដេញថ្លៃឡើយ។ យើងខ្ញុំក៏មិនប្រើវិធីមិនស្មោះត្រង់ដើម្បីបំបាត់គូប្រជែងពីទីផ្សារ ឬរាំងមិនឱ្យចូលទីផ្សារទេ។

4.3 ស្តីពីការជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញឱ្យយើងខ្ញុំ និងអ្នកដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាការងារបន្ត យើងខ្ញុំធ្វើសេចក្តីសម្រេចជ្រើសរើសអ្នកដែលជាដៃគូនោះ ដោយធ្វើការប្រៀបធៀប និងវាយតម្លៃនូវតម្លៃ គុណភាព ល័ក្ខខ័ណ្ឌនៃសេវាកម្ម ដោយយុត្តិធម៌។ យើងខ្ញុំមិនប្រព្រឹត្តអំពើដែលផ្តល់ផលប្រយោជន៍ទុច្ចរិតចំពោះភាគីដៃគូនៃប្រតិបត្តិការ តាមរយៈការប្រើឋានៈអាទិភាពក្នុងប្រតិបត្តិការទិញឡើយ។

4.4 យើងខ្ញុំខំប្រឹងប្រែងទទួលខុសត្រូវចំពោះមុខសង្គម ក្នុងការរក្សាការពារបរិស្ថាន និងការពារសិទ្ធិមនុស្សជាដើម ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញឱ្យយើងខ្ញុំ និងអ្នកដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យាការងារបន្តជាដើម។

4.5 ស្តីពីទម្លាប់ក្នុងអាជីវកម្ម ឬការគួរសម ដូចជា ការជូនអំណោយ ឬបដិសណ្ឋារកិច្ច ឬប្រាក់ជាដើមទេ យើងខ្ញុំត្រូវប្រព្រឹត្តិទៅតាមទម្លាប់ល្អ។

4.6 យើងខ្ញុំមិនជូនអំណោយ ឬមិនធ្វើបដិសណ្ឋារកិច្ច ឬមិនឱ្យជាប្រាក់ ឬកម្រៃផ្សេង ដោយមិនត្រឹមត្រូវចំពោះមន្ត្រីសាធារណៈ ជាអាទិ៍ ដោយមិនគិតដល់មធ្យោបាយ។ យើងខ្ញុំរក្សានូវទំនាក់ទំនងល្អធម្មតានឹងរដ្ឋាភិបាល ព្រមទាំងមន្ត្រីសាធារណៈ។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីលទ្ធកម្ម
2. គោលការណ៍ជារួមក្នុងក្រុមសម្រាប់អ្នកផ្គត់ផ្គង់
3. គោលការណ៍ជារួមក្នុងក្រុមស្តីពីការសូកប៉ាន់
4. គោលការណ៍ជារួមក្នុងក្រុមស្តីពីសកម្មភាពនយោបាយ ឬវិភាគទាននយោបាយ

## 5. សកម្មភាពពាក់ព័ន្ធនឹងសិទ្ធិមនុស្ស

5.1 យើងធ្វើសកម្មភាពអាជីវកម្មដោយផ្អែកលើសិទ្ធិមនុស្សដែលអន្តរជាតិទទួលស្គាល់ ហើយគោរពបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

5.2 យើងខ្ញុំខំប្រឹងប្រែងសហប្រតិបត្តិការនឹងម្ចាស់ហ៊ុនយ៉ាងទូលំទូលាយ ដើម្បីកុំឱ្យចូលរួមក្នុងការបំពានសិទ្ធិមនុស្ស។

5.3 យើងខ្ញុំគោរពគោលការណ៍មូលដ្ឋាននិងសិទ្ធិកន្លែងធ្វើការដូចតទៅ ៖ យើងខ្ញុំ (a)ទទួលស្គាល់នូវសិទ្ធិសេរីភាពក្នុងការបង្កើតសហជីព និងការចរចាជាសមូហភាព, (b)ហាមប្រើកម្លាំងពលកម្មដោយបង្ខំទោះជាក្នុងទម្រង់ណាក៏ដោយ, (c)ហាមប្រើកម្លាំងពលកម្មកុមារ, និង (d)មិនអត់ឱនចំពោះការរើសអើងក្នុងការជួលបុគ្គលិកឡើយ។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីសិទ្ធិមនុស្ស

## 6. ការបណ្តុះបណ្តាលបុគ្គលិក និង ការធានាសុវត្ថិភាព

6.1 ក្រុមហ៊ុននីមួយៗនៃ Ajinomoto Group ត្រូវខំប្រឹងប្រែងផ្តល់ឱកាសការងារ និងផ្តល់ឱកាសអភិវឌ្ឍចំពោះបុគ្គលិក ដើម្បីឱ្យអ្នកទាំងនោះអាចអភិវឌ្ឍនិងបញ្ចេញសមត្ថភាព និងទេពកោសល្យរបស់ខ្លួនដោយគោរពនូវភាពសំបូរបែប លក្ខណៈសម្បត្តិ និងបុគ្គលិកលក្ខណៈរបស់អ្នកទាំងនោះ។

6.2 យើងខ្ញុំត្រូវមានចក្ខុវិស័យជាសកល ឱ្យតម្លៃទៅលើការធ្វើការងារជាក្រុម បញ្ចេញគំនិតច្នៃប្រឌិត និងឧត្តមគតិជាអ្នកត្រួសត្រាយផ្លូវ និងខំប្រឹងប្រែងក្នុងការធ្វើវិភាគទានដើម្បីអភិវឌ្ឍ Ajinomoto Group របស់យើងខ្ញុំទាំងមូល។

6.3 យើងខ្ញុំត្រូវខំប្រឹងប្រែងធ្វើវិភាគទានដើម្បីឱ្យជីវភាពរស់នៅរបស់បុគ្គលិកម្នាក់បានល្អ ហើយធ្វើឱ្យសង្គមរុងរឿង តាមរយៈការអភិវឌ្ឍឱ្យសហគ្រាសមាននិរន្តរភាព។ ហើយចុងបញ្ចប់ យើងខ្ញុំត្រូវខំប្រឹងប្រែងជាប្រចាំដើម្បីអភិវឌ្ឍខ្លួនឯង តាមរយៈគំនិតនិងកម្មវិធីថ្មីៗ។

6.4 យើងខ្ញុំចង់ឱ្យខ្យល់អាកាសកន្លែងធ្វើការល្អ ដើម្បីលើកកំពស់ភាពស្របចិត្តនឹងការងារ ហើយបង្កើនផលិតភាព។

6.5 យើងខ្ញុំគោរពច្បាប់និងបទដ្ឋានគតិយុត្ត និងវប្បធម៌នៃប្រទេស ឬតំបន់ដែលយើងខ្ញុំធ្វើអាជីវកម្ម។ យើងខ្ញុំមិនរើសអើងពូជសាស្ត្រ ជនជាតិ សញ្ជាតិ សាសនា ជំនឿ កន្លែងកំណើត យែនឌ័រ អាយុ ចំណង់ផ្លូវភេទ ពិការភាព អត្តសញ្ញាណ LGBT ជាដើម ឡើយ។

6.6 យើងខ្ញុំត្រូវខំប្រឹងប្រែងរៀបចំកន្លែងធ្វើការឱ្យមានផាសុខភាព និងមានទំនាក់ទំនងគ្នាជាចំហរ ដែលគ្មានការរើសអើង គ្មានការយាយី ហើយដែលក្នុងនោះ មនុស្សគោរពនូវភាពថ្លៃថ្នូរទៅវិញទៅមក។

6.7 យើងខ្ញុំគោរពមនុស្សម្នាក់ៗ ហើយចាត់ទុកសុវត្ថិភាពនិងសុខភាពកន្លែងការងារ ជាកត្តាសំខាន់ជាងគេនៃសកម្មភាពរបស់ក្រុមហ៊ុន។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីធនធានមនុស្ស
2. គោលការណ៍ជារួមក្នុងក្រុមស្តីពីសុវត្ថិភាពនិងសុខភាពការងារ

## 7. ធ្វើការងារនឹងសហគមន៍

7.1 យើងខ្ញុំខំប្រឹងប្រែងធ្វើវិភាគទានជាវិជ្ជមានចំពោះសង្គម ក្នុងការបង្កើតសហគមន៍ដែលយើងប្រកបអាជីវកម្ម ឱ្យមានសុខភាពល្អ និងឆ្លងទៅសង្គមផ្សេងទៀត។ យើងចាប់អារម្មណ៍ទៅលើការអភិវឌ្ឍវប្បធម៌ និងអប់រំនៃសហគមន៍នីមួយៗដែលយើងធ្វើអាជីវកម្ម។

7.2 យើងខ្ញុំម្នាក់ៗត្រូវខំប្រឹងប្រែងចូលរួមធ្វើសកម្មភាពដែលជាវិភាគទានដល់សង្គម ក្នុងនាមជាសមាជិកម្នាក់នៃសង្គមក្នុងតំបន់។

7.3 យើងខ្ញុំយល់ដឹងថា រាល់ពេលដែលអ្នកណាម្នាក់ ឬបុគ្គលិកណាម្នាក់នៃក្រុមយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងនឹងសាធារណជន គឺអ្នកនោះធ្វើសកម្មភាពក្នុងនាមជាតំណាងក្រុមហ៊ុន ហើយសកម្មភាពទាំងនោះត្រូវបានគ្រប់គ្រងដោយឥរិយាបទសង្គមជារៀងរាល់ពេល។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីការពង្រឹងសហគមន៍

## 8. ការទទួលខុសត្រូវចំពោះម្ចាស់ហ៊ុននិងវិនិយោគិន

8.1 យើងខ្ញុំត្រូវជម្រុញការគ្រប់គ្រងឱ្យបានល្អ បែងចែកផលចំណេញជូនម្ចាស់ហ៊ុនឱ្យបានសមរម្យ និងពង្រីកតម្លៃរបស់សហគ្រាសឱ្យមាននិរន្តរភាព។

8.2 យើងខ្ញុំត្រូវបញ្ចេញព័ត៌មានឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ជូនចំពោះម្ចាស់ហ៊ុន និងវិនិយោគិនជាដើម ដើម្បីឆ្លើយតបឱ្យមានសមភាព និងស្មោះត្រង់ ទៅតាមការរំពឹងទុក និងទំនុកចិត្តរបស់គេ។

8.3 យើងខ្ញុំត្រូវរក្សា និងដំណើរការក្របខ័ណ្ឌគ្រប់គ្រងផ្ទៃក្នុងសមស្រប ដើម្បីធានានូវជំនឿនិងភាពត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុដែលយើងខ្ញុំបានជូនចំពោះម្ចាស់ហ៊ុននិងវិនិយោគិន។

8.4 យើងខ្ញុំមិនបំពានច្បាប់ស្តីពីប្រតិបត្តិការដោយមានរណុកក្នុង ដូចជាការជួញដូរភាគហ៊ុន ជាដើមដោយប្រើព័ត៌មានដែលមិនប្រកាសជាសាធារណៈ របស់ក្រុមហ៊ុននីមួយៗនៃ Ajinomoto Group យើងខ្ញុំ ឬ/និងរបស់ដៃគូនៃប្រតិបត្តិការដែលលក់ហ៊ុនក្នុងទីផ្សារហ៊ុនឡើយ។

8.5 យើងខ្ញុំគោរពតាមច្បាប់ពន្ធដារនៃប្រទេសនីមួយៗដែលយើងខ្ញុំដំណើរការ។ យើងខ្ញុំឆ្លើយតបទៅនឹងការប្រែប្រួលនៃប្រព័ន្ធពន្ធដារនិងប្រព័ន្ធរដ្ឋបាល ព្រមទាំងធ្វើឱ្យហានិភ័យពន្ធដារមានជាអប្បបរមា ដើម្បីបង្កើនតម្លៃជាអតិបរមានូវតម្លៃរបស់ម្ចាស់ហ៊ុននិងវិនិយោគិន។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីពន្ធដារក្នុងសកលលោក
2. គោលការណ៍ជារួមក្នុងក្រុមស្តីពីការចែករំលែកព័ត៌មានជាមួយនឹងម្ចាស់ហ៊ុននិងវិនិយោគិន

## 9. ការការពារនិងគ្រប់គ្រងទ្រព្យសម្បត្តិនិងព័ត៌មានរបស់ក្រុមហ៊ុន

9.1 យើងខ្ញុំត្រូវការពារ និងគ្រប់គ្រងទ្រព្យសម្បត្តិទាំងរូបិយ ទាំងអរូបិយ រួមទាំងការសម្ងាត់ និងកម្មសិទ្ធិបញ្ញារបស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ។

9.2 យើងខ្ញុំយល់អំពីសារៈសំខាន់នៃការការពារព័ត៌មានរបស់បុគ្គលឯកជន ហើយទទួលយក ប្រើប្រាស់ និងផ្តល់ព័ត៌មានរបស់បុគ្គលឯកជនដោយសមស្របដើម្បីការពារការលេចចេញនូវព័ត៌មាន។

9.3 យើងខ្ញុំយល់ថា ម៉ាកសញ្ញារបស់ក្រុមហ៊ុន កម្មសិទ្ធិបញ្ញាដែលក្រុមហ៊ុនមាន គឺជាទ្រព្យសម្បត្តិដ៏សំខាន់របស់ក្រុមហ៊ុនយើងខ្ញុំ ហើយប្រើទ្រព្យទាំងនេះឱ្យត្រឹមត្រូវសមរម្យទៅតាមច្បាប់ និងតាមវិន័យផ្ទៃក្នុងរបស់ Ajinomoto Group។

9.4 យើងខ្ញុំត្រូវគោរពកម្មសិទ្ធិបញ្ញាត្រឹមត្រូវ របស់តតិយជន។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីសុវត្ថិភាពព័ត៌មាន
2. គោលការណ៍ជារួមក្នុងក្រុមស្តីពីឯកជនភាព
3. គោលការណ៍ជារួមក្នុងក្រុមស្តីពីកម្មសិទ្ធិបញ្ញា

## 10. ការបែងចែកឱ្យដាច់ នូវបញ្ហាឯកជននិងបញ្ហាអាជីវកម្ម

10.1 យើងខ្ញុំត្រូវខំប្រឹងប្រែងធ្វើកុំឱ្យមានទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន រួមទាំងគ្រួសារទៅនឹងផលប្រយោជន៍របស់ Ajinomoto Group។

10.2 យើងខ្ញុំប្រើទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ក្រុមហ៊ុនតែសម្រាប់គោលបំណងអាជីវកម្មប៉ុណ្ណោះ ហើយមិនប្រើសម្រាប់ស្វែងរកផលប្រយោជន៍របស់បុគ្គលឡើយ។

10.3 យើងខ្ញុំយល់ច្បាស់ថា ទំនាក់ទំនងអាជីវកម្មដែលត្រូវបានបង្កើតឡើងដោយបុគ្គលិកគឺជារបស់ក្រុមហ៊ុន ទោះជាក្រោយពេលបុគ្គលិកនោះចូលនិវត្តក៏ដោយ។

10.4 ពេលដែលបញ្ចេញព័ត៌មានតាមរយៈមេឌៀសង្គម យើងខ្ញុំត្រូវបែងចែកឱ្យបានច្បាស់លាស់ថា តើជាការផ្សាយព័ត៌មានជាសាធារណៈរបស់ក្រុមហ៊ុន ឬជាការផ្សាយព័ត៌មានរបស់បុគ្គល។ ទោះជាពេលផ្សាយព័ត៌មានរបស់បុគ្គលក៏ដោយ ក៏យើងខ្ញុំត្រូវមានការទទួលខុសត្រូវក្នុងនាមជាសមាជិកម្នាក់នៃ Ajinomoto Group ហើយមិនធ្វើឱ្យបាត់បង់នូវទំនុកចិត្តចំពោះក្រុមហ៊ុន ឈ្មោះរបស់ក្រុមហ៊ុន ឬធ្វើឱ្យខូចទ្រព្យសម្បត្តិផ្សេងទៀតរបស់ក្រុមហ៊ុនឡើយ។

10.5 ស្តីពីសកម្មភាពនយោបាយ យើងខ្ញុំត្រូវធ្វើសកម្មភាពទាំងនេះក្នុងនាមជាបុគ្គល ហើយធ្វើនៅក្រៅកន្លែងរបស់ក្រុមហ៊ុន និងក្រៅម៉ោងធ្វើការ។

## 11. ការរៀបចំនិងការអនុវត្តអភិបាលកិច្ចល្អ

11.1 យើងខ្ញុំបង្កើតប្រព័ន្ធអធិការកិច្ចដែលមានគណកម្មការតំណាង គណនេយ្យភាព ព្រមទាំងគ្រប់គ្រងក្រុមហ៊ុនក្នុងក្រុម តាមវិធីដែលមានសមធម៌ តម្លាភាព និងមានប្រសិទ្ធិភាពដើម្បីបង្កើនតម្លៃរបស់ក្រុមហ៊ុនជានិរន្តរ។

11.2 យើងខ្ញុំអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ និងរៀបចំគ្រប់គ្រងហានិភ័យដើម្បីត្រៀមចំពោះបញ្ហានយោបាយ សេដ្ឋកិច្ច និងសង្គម ដូចជាភេរវកម្ម ការវាយប្រហារតាមអ៊ីនធឺណិត និងគ្រោះធម្មជាតិ។

11.3 យើងខ្ញុំដាច់ខាតមិនចូលពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋកម្មណាមួយដែលធ្វើឱ្យខូចសណ្តាប់ធ្នាប់ និងសន្តិសុខប្រជាពលរដ្ឋឡើយ។ យើងខ្ញុំតាំងចិត្តប្រឆាំងនឹងក្រុមឧក្រិដ្ឋកម្មហើយមិនឆ្លើយតបចំពោះការទាមទារមិនត្រឹមត្រូវជាដាច់ខាត។

11.4 ក្នុងករណីដែលយើងខ្ញុំជាប់ពាក់ព័ន្ធនឹងអំពើឆបោក ឬអំពើផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្ត ឬផ្ទុយនឹង AGP យើងខ្ញុំនឹងប្រកាស។ យើងខ្ញុំនឹងពិគ្រោះជាមួយនឹងថ្នាក់ដឹកនាំសមស្រប ហើយប្រើប្រព័ន្ធផ្តល់របាយការណ៍អនាមិករបស់យើងខ្ញុំ ដើម្បីស្រាវជ្រាវអំពីអំពើ ឬបញ្ហានោះឱ្យបានច្បាស់លាស់។

**គោលការណ៍ជារួមក្នុងក្រុម**

1. គោលការណ៍ជារួមក្នុងក្រុមស្តីពីអភិបាលកិច្ច
2. គោលការណ៍ជារួមក្នុងក្រុមស្តីពីការគ្រប់គ្រងហានិភ័យ
3. គោលការណ៍ជារួមក្នុងក្រុមស្តីពីគណនេយ្យ
4. គោលការណ៍ជារួមក្នុងក្រុមស្តីពីការបង្ការការឆបោក និងការបន្លំលួចប្រាក់
5. គោលការណ៍ជារួមក្នុងក្រុមស្តីពីការធ្វើរបាយការណ៍អនាមិក

**អ្វីៗក៏ដោយ ពាក់ព័ន្ធនឹង Ajinomoto Group Policies (AGP) សូមទាក់ទងមក :**

ក្រុមហ៊ុន Ajinomoto Co., Inc
លេខាធិការដ្ឋានគណកម្មាធិការក្រុមប្រតិបត្តិនៃសហគ្រាស នាយកដ្ឋានច្បាប់និងការគោរពច្បាប់
អាសយដ្ឋាន : 1-15-1 Kyobashi, Chuo-ku, Tokyo, 104-8315

### របាយការណ៍

- បន្ថែមលើបណ្តាញហិតឡាញទៅក្រុមហ៊ុននីមួយៗ របាយការណ៍នានាក៏អាចធ្វើទៅតាមបណ្តាញខាងក្រោមនេះដែរ។

**បណ្តាញហិតឡាញខាងក្រៅសម្រាប់ប្រទេសជប៉ុន**

TEL : 0120-783-805 (មិនយកថ្លៃទូរស័ព្ទទេ)
អាចប្រើពី 9:00-21:00
លេខកូដ : 332 ឈ្មោះ : Ajinomoto Group
គេហទំព័រ : https://ml.helpline.jp/a-hotline
ID : hotline PW : ajinomoto

**បណ្តាញហិតឡាញគណកម្មការអធិការកិច្ច**

គេហទំព័រ : https://i365.helpline.jp/ajinomoto/k-hotline
លេខកូដ : 332 ឈ្មោះ : Ajinomoto Group
ID : hotline PW : ajinomoto

បណ្តាញហិតឡាញគណកម្មការអធិការកិច្ចត្រូវបានដំណើរការដោយគណកម្មការអធិការកិច្ច ហើយសម្រាប់តែធ្វើរបាយការណ៍ស្តីពីការអនុវត្តមុខងាររបស់បុគ្គលិក។ រីឯខ្លឹមសារនៃរបាយការណ៍វិញ លេខាធិការដ្ឋានគណកម្មការដំណើរការអាជីវកម្មជាអ្នកទទួលខុសត្រូវឆ្លើយ។

**បណ្តាញហិតឡាញខាងក្រៅសម្រាប់ក្រៅប្រទេសជប៉ុន**

គេហទំព័រ : https://ml.helpline.jp/g-hotline
ID : hotline PW : ajinomoto

**បណ្តាញហិតឡាញខាងក្នុងសម្រាប់ប្រទេសជប៉ុន : លេខាធិការដ្ឋាននៃគណកម្មការដំណើរការអាជីវកម្ម, AJICO**

TEL/FAX: +81-3-5250-8244 E-mail: hotline@asv.ajinomoto.com

**Ajinomoto Co., Inc.**
15-1, Kyobashi 1-chome, Chuo-ku,
Tokyo 104-8315 Japan
Tel: +81 (3) 5250-8111
URL: http://www.ajinomoto.com/en/

Eat Well, Live Well.

AJINOMOTO

ធ្វើនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨
កំណែទី២ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១